# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងសុខាភិបាល
**គម្រោងបណ្តុះបណ្តាលមុនពេលចូលបម្រើការងារសម្រាប់បុគ្គលិកសុខាភិបាល** (P169629)
**ផែនការចូលរួមរបស់ភាគីពាក់ព័ន្ធ**

## សេចក្តីសង្ខេប

ផែនការចូលរួមរបស់ភាគីពាក់ព័ន្ធ (Stakeholder Engagement Plan) គឺជាឧបករណ៍ទីពីរ សម្រាប់ក្របខ័ណ្ឌបរិស្ថាន និងសង្គម (Environmental and Social Framework) ដែលបានរៀបចំ ពិគ្រោះយោបល់ និងផ្សព្វផ្សាយដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់គម្រោង "បណ្តុះបណ្តាលមុនពេលចូលបម្រើការងារសម្រាប់បុគ្គលិកសុខាភិបាល" នៅប្រទេសកម្ពុជា។ ឧបករណ៍នេះអនុវត្តជាពិសេសទៅតាមតម្រូវការនៃស្តង់ដារបរិស្ថាន និងសង្គម (Environment and Social Standard or ESS10) របស់ធនាគារពិភពលោកស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការបង្ហាញព័ត៌មានជាសាធារណៈ។

គោលបំណងនៃផែនការចូលរួមរបស់ភាគីពាក់ព័ន្ធ គឺដើម្បីផ្តល់ការចូលរួមប្រកបដោយតម្លាភាព និងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកដោយបើកចំហរវាង និងក្នុងចំណោមភាគីពាក់ព័ន្ធគម្រោងដើម្បីបង្កើនការចូលរួម និងបរិយាបន្ននៃការរៀបចំ ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោង និងលើកកម្ពស់ការទទួលយកគម្រោង និងលើកកម្ពស់និរន្តរភាពនៃបរិស្ថាន និងសង្គម។ វិធីសាស្ត្រជាប្រព័ន្ធចំពោះការចូលរួមរបស់ភាគីពាក់ព័ន្ធនឹងជួយឱ្យក្រសួងសុខាភិបាលបង្កើត និងរក្សាទំនាក់ទំនងប្រកបដោយការស្ថាបនាជាមួយភាគីពាក់ព័ន្ធក្នុងរយៈពេលនៃគម្រោង។

សមាសធាតុសំខាន់ៗចំនួនបួននៃផែនការចូលរួមរបស់ភាគីពាក់ព័ន្ធរួមមាន៖

1. ការកំណត់ភាគីពាក់ព័ន្ធនៃគម្រោង និងការវិភាគតួនាទី ផលប្រយោជន៍ និងឥទ្ធិពលរបស់ពួកគេនៅក្នុងគម្រោង។
   ផ្នែកនេះបានកំណត់ក្រុមអ្នកពាក់ព័ន្ធ ដែលទំនងជាប៉ះពាល់ ឬរងផលប៉ះពាល់ពីសកម្មភាពគម្រោង និងបែងចែកពួកគេដោយផ្អែកលើផលប៉ះពាល់របស់ពួកគេលើគម្រោង "បណ្តុះបណ្តាលមុនពេលចូលបម្រើការងារសម្រាប់បុគ្គលិកសុខាភិបាល" និងផលប៉ះពាល់ពីសកម្មភាពគម្រោងដែលនឹងមានទៅលើពួកគេ។ ការកំណត់ភាគីពាក់

ព័ន្ធនៃគម្រោង នឹងជាដំណើរការដែលកំពុងបន្តដែលអាចវិវឌ្ឍ នៅពេលដែលមានភាគីពាក់ព័ន្ធថ្មីៗត្រូវបានណែនាំដល់គម្រោង។ ការវិភាគអំពីភាគីពាក់ព័ន្ធជាបឋមបានកំណត់នូវផលប្រយោជន៍ផ្សេងៗរបស់ក្រុមភាគីពាក់ព័ន្ធនានា និងឥទ្ធិពលក្រុមទាំងនេះដែលអាចមានមកលើគម្រោង។ ការវិភាគនេះ ក៏មានឥទ្ធិពលលើការរៀបចំសកម្មភាពនៃការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងថាតើភាគីពាក់ព័ន្ធណាខ្លះដែលត្រូវចូលរួម និងពេលណាដែលពួកគេត្រូវចូលរួម។

2. ផែនការចូលរួមរបស់ភាគីពាក់ព័ន្ធ
ផ្នែកនេះរៀបរាប់លម្អិតអំពីយុទ្ធសាស្ត្រផ្លូវការ ដើម្បីប្រាស្រ័យទាក់ទងជាមួយភាគីពាក់ព័ន្ធគម្រោងដើម្បីចូលរួម និងគាំទ្រដល់គម្រោង "បណ្តុះបណ្តាលមុនពេលចូលបម្រើការងារសម្រាប់បុគ្គលិកសុខាភិបាល"។ ផែនការនេះបញ្ជាក់ពីពេលវេលា ចំនួន និងប្រភេទនៃការទំនាក់ទំនង ប្រព័ន្ធផ្សព្វផ្សាយ អ្នកដែលត្រូវទំនាក់ទំនង និងទីតាំងនៃព្រឹត្តិការណ៍ទំនាក់ទំនង។

3. យន្តការបណ្តឹងសារទុក្ខ
ផ្នែកនេះរៀបរាប់លម្អិតអំពីយន្តការបណ្តឹងសារទុក្ខ ដែលអនុញ្ញាតឱ្យអ្នកដែលមានបណ្តឹងតវ៉ា ឬអ្នកដែលមានអារម្មណ៍មិនពេញចិត្តនឹងគម្រោងនេះ អាចបញ្ជូនការព្រួយបារម្ភ និង/ឬសារទុក្ខរបស់ពួកគេតាមរយៈដំណើរការមួយសមស្រប។ យន្តការបណ្តឹងសារទុក្ខនឹងផ្តល់នូវការឆ្លើយតបដែលមានភាពងាយស្រួលប្រើប្រាស់បាន មានភាពរហ័ស មានយុត្តិធម៌ និងមានប្រសិទ្ធភាពចំពោះភាគីពាក់ព័ន្ធ ជាពិសេសក្រុមងាយរងគ្រោះដែលជារឿយៗខ្វះលទ្ធភាពក្នុងការទទួលបានការគាំទ្រផ្នែកផ្លូវច្បាប់។ យន្តការបណ្តឹងសារទុក្ខមានគោលបំណង ដើម្បីសម្រេចបាននូវដំណោះស្រាយនៃបណ្តឹងសារទុក្ខ ដែលបានព្រមព្រៀងគ្នាទៅវិញទៅមកចំពោះភាគីពាក់ព័ន្ធគម្រោង អ្នកចូលរួម និងអ្នកទទួលផលពីគម្រោង ហើយធានាថាបណ្តឹងតវ៉ា និងបណ្តឹងសារទុក្ខត្រូវបានដោះស្រាយដោយភាពស្មោះត្រង់ និងតាមរយៈដំណើរការប្រកបដោយតម្លាភាព និងមិនលំអៀង ជាមួយនឹងដំណោះស្រាយណាមួយដែលអាចទទួលយកបានដោយភាគីទាំងសងខាង។ យន្តការបណ្តឹងសារទុក្ខមិនដោះស្រាយចំពោះ "ក្តីបារម្ភនានា" ដែលត្រូវបានកំណត់ថាជាសំណួរ ការស្នើសុំព័ត៌មាន ឬការយល់ឃើញដែលមិនទាក់ទងចាំបាច់នឹងផលប៉ះពាល់ ឬព្រឹត្តិការណ៍ជាក់លាក់ណាមួយ ដែលបណ្តាលមកពីសកម្មភាព

គម្រោង។ ប្រសិនបើមិនបានដោះស្រាយចំពោះការពេញចិត្តរបស់បុគ្គល ឬក្រុមដែលលើកឡើងពីកង្វល់ទេនោះ កង្វល់មួយអាចក្លាយជាបណ្តឹងតវ៉ានៅពេលក្រោយ។

4. នីតិវិធីសម្រាប់ការតាមដានត្រួតពិនិត្យ និងការធ្វើរបាយការណ៍ជូនភាគីពាក់ព័ន្ធ
ដំណើរការនៃការចូលរួមរបស់ភាគីពាក់ព័ន្ធនឹងជំរុញការអភិវឌ្ឍផ្នែកទំនាក់ទំនងប្រកបដោយភាពស្ថាបនា និងការឆ្លើយតបកាន់តែមានភាពរឹងមាំក្នុងចំណោមភាគីពាក់ព័ន្ធគម្រោងសំខាន់ៗដែលបានកំណត់ ដើម្បីឱ្យការគ្រប់គ្រងនូវការអនុវត្តគម្រោងប្រកបដោយជោគជ័យ។ ការចូលរួមរបស់ភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាពរវាងរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធគម្រោងនានា ធ្វើឱ្យប្រសើរឡើងនូវនិរន្តរភាពនៃបរិស្ថាន និងសង្គមរបស់គម្រោង លើកកម្ពស់ការទទួលយកគម្រោង និងចូលរួមចំណែកយ៉ាងសំខាន់ដល់ការរៀបចំ និងការអនុវត្តគម្រោង ″បណ្តុះបណ្តាលមុនពេលចូលបម្រើការងារសម្រាប់បុគ្គលិកសុខាភិបាល″ ប្រកបដោយជោគជ័យ។

ការធ្វើរបាយការណ៍ជូនភាគីពាក់ព័ន្ធ គឺជាប់ទាក់ទងនឹងការផ្តល់នូវព័ត៌មានលម្អិតសំខាន់ៗស្តីពីការអនុវត្ត សកម្មភាពការងារជាប្រចាំ ស្ថានភាព និងវឌ្ឍនភាពរបស់ក្រុមការងារអនុវត្តគម្រោង និងវឌ្ឍនភាពរបស់គម្រោង។ ការធ្វើរបាយការណ៍ជូនអ្នកពាក់ព័ន្ធក៏អាចបញ្ចូលនូវព័ត៌មានថ្មីៗ ឬព័ត៌មានដែលបានកែតម្រូវចាប់តាំងពីរបាយការណ៍ចុងក្រោយមក។ ការតាមដានការប្តេជ្ញាចិត្ត ដែលធ្វើឡើងចំពោះក្រុមភាគីពាក់ព័ន្ធនានានៅតាមពេលវេលាផ្សេងៗគ្នា និងវឌ្ឍនភាពនៃការប្រាស្រ័យទាក់ទងដែលស្របនឹងការប្តេជ្ញាចិត្តទាំងនេះជាប្រចាំ គឺទាមទារឱ្យមានការធ្វើផែនការ និងការរៀបចំ។

# សកម្មភាពចូលរួមរបស់ភាគីពាក់ព័ន្ធបានធ្វើក្នុងអំឡុងពេលនៃដំណាក់កាលត្រៀមរៀបចំ

| សកម្មភាព | ស្ថាប័ន | ចំនួនអ្នកចូលរួម | | |
|---|---|---|---|---|
| | | សរុប | ស្ត្រី | ក្រុមដែលជួបការលំបាក |
| ១.ក្រុមពិភាក្សា | វិទ្យាស្ថានបណ្តុះបណ្តាលសុខាភិបាល (សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែង) | ១៣១ | ៨១ | ៥ |
| | ស្ថាប័នសុខាភិបាលសាធារណៈ (មន្ទីរពេទ្យរដ្ឋ មន្ទីរសុខាភិបាល) | ៧១ | ២៤ | ១ |
| | ក្រុមដែលជួបការលំបាក (អ្នកមានពិការភាព អ្នកស្រឡាញ់ភេទដូចគ្នា) | ៩ | ២ | ៨ |
| | *សរុបអ្នកចូលរួមក្រុមពិភាក្សា* | *២១១* | *១០៧* | *១៤* |
| ២. កិច្ចប្រជុំពិគ្រោះយោបល់ | ភាគីពាក់ព័ន្ធផ្សេងៗ | ២៤ | ៨ | ៣ |